# របាយការណ៍ស្តីពីទីតាំងពិឃាតនៅវត្តអំពែភ្នំ ស្រុក និង ខេត្តកំពង់ស្ពឺ

ដោយ ដេង ពងរ៉ាស៊ី

ព្រលឹមថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០០ ក្រុមផែនទីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរួមដំណើរជាមួយក្រុមថតខ្សែភាពយន្តឯកសាររបស់លោកឫទ្ធី ប៉ាន់ឆ្ពោះទៅកាន់វត្តអំពែភ្នំ ដែលស្ថិតនៅក្នុងភូមិអំពែភ្នំ ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។ គោលបំណងនៃការធ្វើដំណើរគឺចង់ស្រាវជ្រាវបន្ថែមទៅលើទីតាំងដែលបានសិក្សារួចកាលពីឆ្នាំ១៩៩៧ និង ម្យ៉ាងដើម្បីរួមសហការថតជាខ្សែភាពយន្តឯកសារផង ។

## ១) បូជនីយដ្ឋានវត្តអំពែភ្នំ[១]

នៅទីតាំងវត្តអំពែភ្នំសព្វថ្ងៃនេះ បានបន្សល់ទុកនូវទីតាំងតំកល់អដ្ឋិធាតុយ៉ាងកញ្ចាស់មួយ ប្រក់ក្បឿង មានជញ្ជាំងក្តារពុកៗនិងគ្មានទ្វារបង្អួចត្រឹមត្រូវ ឈរយ៉ាងជ្រងទ្រេតទ្រោតទ្រង់ថ្ងៃដែលមានទីតាំងស្ថិតនៅប៉ែកខាងលិចវត្តជាប់នឹងទីតាំងសម្លាប់សម័យខ្មែរក្រហម ។មានអដ្ឋិធាតុជាច្រើនបានគរជាពំនូកចំកណ្តាលបូជនីយដ្ឋាននោះ ។ ឆ្អឹងទាំងប៉ុន្មាន(មានរូបថតភ្ជាប់) សុទ្ធតែត្រូវបានគាស់ចេញពីរណ្តៅរាប់រយខាងលិចវត្តប្រហែលជាង១០០ម៉ែត្រ ដែលសព្វថ្ងៃមិនបានបន្សល់ស្លាកស្នាមអ្វីទាំងអស់ ។ ដោយសារការគាស់ឆ្អឹងខាងលើនេះហើយទើបមានការសង់រោងសម្រាប់ដាក់អដ្ឋិធាតុទាំងនោះនៅឆ្នាំ១៩៨៦ក្រោមរូបភាពរៃអង្គាសថវិកាចំនួន៣០០០រៀលពីគ្រប់វត្តក្នុងស្រុកតាមបញ្ជារបស់លោកចៅហ្វាយស្រុកឈ្មោះឆាយ ខេង ។ អដ្ឋិធាតុដែលបានយកមកតំកល់ទុកនៅក្នុងបូជនីយដ្ឋាននេះ មិនបានបញ្ជូនមកភាគច្រើនពីកន្លែងដទៃទេគឺមានតែមួយភាគតូចប៉ុណ្ណោះ ដែលបានបញ្ជូនមកពីបន្ទាយរោងគោ[២] ។

## ២) ទីតាំងសម្លាប់វត្តអំពែភ្នំ[៣]

១ នៅក្នុងរបាយការណ៍ផែនទីរណ្តៅសាកសពឆ្នាំ១៩៩៧ ទីតាំងបន្ទាយរោងគោមានលេខកូតភូមិសាស្រ្តតាមរយៈទទឹង១០៤ ៣២ ២៩៣៨ និងរយៈកំពស់ ១១ ២៧ ១១២៩ ។

២ នៅក្នុងរបាយការណ៍ផែនទីរណ្តៅសាកសពឆ្នាំ១៩៩៧ ទីតាំងបន្ទាយរោងគោមានលេខកូតភូមិសាស្រ្តតាមរយៈទទឹងៈ១០៤ ៣១ ៤២៤២ និងរយៈកំពស់ ១១ ២៧ ៣៦៨៦ ។

៣ នៅក្នុងរបាយការណ៍ផែនទីរណ្តៅសាកសពឆ្នាំ១៩៩៧ ទីតាំងបន្ទាយរោងគោមានលេខកូតភូមិសាស្រ្តតាមរយៈទទឹង១០៤ ៣២ ២៩៣៨ និងរយៈកំពស់ ១១ ២៧ ១១២៩ ។

ទីតាំងសម្លាប់ស្ថិតនៅប៉ែកខាងលិចព្រះវិហារ ហើយក៏មានខ្លះៗនៅខាងកើតព្រះវិហារដែរ ។ ព្រះតេជគុណព្រះនាម សុផល ហៅ ញ៉ែម ស៊ីន ព្រះជន្ម៧១ព្រះវស្សា បានមានពុទ្ធដីការថា ទីតាំងសម្លាប់មានទំហំខាងលិចមួយគីឡូម៉ែត្រ និងខាងកើតដល់ភូមិ មួយគីឡូម៉ែត្រទៀត ។ ក្រោយពេលបែកឆ្នាំ១៩៧៩ទីតាំងខាងលើមានសុទ្ធតែរណ្តៅទាំងអស់ ។ បច្ចុប្បន្នទីវាលពិឃាតមនុស្សនោះបានក្លាយជាដីសម្រាប់ប្រជាកសិករបង្កបង្កើនផលអស់គ្មានសល់ ។ ចំណែកឆ្អឹងរបស់សាកសពត្រូវបានប្រជាជនដែលនៅសេសសល់ពីស្លាប់ នាំគ្នាគាស់មកដាក់នៅកន្លែងតំកល់អដ្ឋិធាតុមួយដែលមានចម្ងាយមិនឆ្ងាយប៉ុន្មានពីទីតាំងសម្លាប់ ។ តាមសម្តីរបស់អ៊ំប្រុសឈ្មោះអ៊ុន ហាក់ អាយុ៧២ឆ្នាំ ជាប្រជាជនរស់នៅភូមិអំពែរភ្នំ ឃុំរលាំងចក ស្រុកសំរោងទង បាននិយាយថាឆ្អឹងដែលបានគាស់កាលពីឆ្នាំ ១៩៧៩-៨០ មានចំនួនច្រើនជាងឆ្អឹងដែលមិនទាន់បានគាស់ ។ នៅមានឆ្អឹងជាច្រើនទៀតដែលបានបាក់ទៅតាមដីចូលទៅក្នុងប្រឡាយទឹកដ៏វែងមួយនៅក្បែរនោះ ។ អ៊ំ ហាក់ បានបន្តថាមានមនុស្សប្រហែលពី២០០០០នាក់បានស្លាប់នៅទីតាំងសម្លាប់ខាងលិចវត្ត ។

## ៣) មន្ទីរសន្តិសុខវត្តអំពែរភ្នំ[៤]

មន្ទីរសន្តិសុខវត្តអំពែរភ្នំ ស្ថិតនៅក្នុងព្រះវិហារវត្តអំពែរភ្នំតែម្តង ។ ព្រះបដិមាករធំជាងគេត្រូវបានពួកខ្មែរក្រហមបាញ់ផ្តាច់ព្រះកេសពីដងខ្លួន ។ព្រះខ្នែនរបស់ព្រះបដិមាករត្រូវបានពួកខ្មែរក្រហមយកធ្វើជាកន្លែងធ្វើទារុណកម្មអ្នកទោសនិងសម្លាប់អ្នកទោសម្តងៗក្នុងករណីអ្នកទោសតមាត់ យំ ស្រែក ។ អ្នកទោសដែលត្រូវបានបញ្ជូនមកកាន់ទីតាំងវត្តនេះ ភាគច្រើនប្រមូលមកពីតំបន់៥៥ ខេត្តតាកែវ និងមានអ្នកមូលដ្ឋានខ្លះ ។ ក្រោយបែកឆ្នាំ១៩៧៩ព្រះវិហារនេះជិតដាមទៅដោយឈាមពាសពេញកម្រាលឥដ្ឋ ។ ចំណែកនៅលើព្រះខ្នែនបដិមាករវិញមានសុទ្ធតែឈាមខាប់ប្រឡាក់ពេញ ។ អ៊ំ ហាក់ បានរំលឹកថានៅពេលដែលគាត់បានចូលមកដល់មុនគេ គាត់បានឃើញមានឈាមពាសពេញទាំងអស់ ។ គំនូរនៅតាមជញ្ជាំងព្រះវិហារត្រូវបានពួកខ្មែរក្រហមលុបដោយទឹកកំបោរស មើលទៅគ្មានឃើញគំនូរឡើយ គឺឃើញមានតែស្នាមលុបនិងឈាមប្រឡាក់ប៉ុណ្ណោះ ។ ចំណែកព្រះពុទ្ធដិមាករភាគច្រើនត្រូវបានបាត់ពីព្រះវិហារ ។ អ្នកទោសដែលបានជាប់នៅមន្ទីរឃុំឃាំងនេះគ្មាននរណាម្នាក់បានរួចខ្លួនឡើយ ។ ចំណែកអ៊ំឈ្មោះ ឆាយ ចេង អាយុ៧០ឆ្នាំ ជាអាចារ្យវត្តអំពែរភ្នំ បាននិយាយថាពួកខ្មែរក្រហមដែលមកយាមអ្នកទោស ធ្វើទារុណកម្មអ្នកទោស អ្នកផលិតថ្នាំអាចម៍ទន្សាយនៅក្នុងបរិវេណទីធ្លាវត្ត

---

៤ នៅក្នុងរបាយការណ៍ផែនទីរណ្តៅសាកសពឆ្នាំ១៩៩៧ ទីតាំងបន្ទាយរោងគោមានលេខកូតភូមិសាស្ត្រតាមរយៈទទឹង១០៤ ៣២ ៣៨៥២ និងរយៈកំពស់ ១១ ២៧ ១៨៩២ ។

*អ្នកដាំស្លឲ្យអ្នកទោសសុទ្ធតែជាជនពិការទាំងអស់ទោះជាមិនដល់ថ្នាក់ដាច់ដៃជើងក៏ដោយ ។ អ៊ឹប្រុសបានបន្ថែមថានៅប៉ែកខាងក្រោយព្រះវិហារប្រមាណ៥០ម៉ែត្រមានកន្លែងធ្វើ ទារុណកម្មអ្នកទោសយ៉ាងសាហាវមួយកន្លែងទៀតស្ថិតនៅជាប់នឹងគល់ឈើមួយដើមយ៉ាងធំក្នុងទីធ្លាវត្ត ។ វិធីធ្វើទារុណកម្មនៅកន្លែងនោះគឺចងដៃទាំងពីររបស់អ្នកទោស(ចងឆ្កាង) ទៅនឹងដែកគោលចំនួនពីរដែលពួកខ្មែរក្រហមបានដំជាប់នឹងគល់ឈើនោះរួចវះពោះ ។ តាមសម្ដីរបស់អ៊ឹចេងថា ពួកខ្មែរក្រហមវះពោះនេះគឺដើម្បីយកថ្លើមនិងប្រមាត់របស់អ្នកទោស ។ អ៊ឹឆាយបន្តថានៅឆ្នាំ១៩៧៨ ទីតាំងវត្តអំពែរភ្នំមានការសម្លាប់មនុស្សច្រើនបំផុត ហើយអ្នកទោសច្រើនយកមកពីតំបន់៥៥ ខេត្តតាកែវ ។ នៅដើមឆ្នាំ១៩៧៩ ពួកខ្មែរក្រហមដែលកាន់នៅវត្តអំពែរភ្នំ បានរត់ចោលទីតាំងដោយបានបន្សល់ទុកនូវថ្នាំសង្កូវ(ថ្នាំអាចម៍ទន្សាយ) ខ្ទះផុកសម្លរពេញ បាយ ប្រហុកព្រមទាំងបានបន្សល់ទុកនូវការខូចខាតយ៉ាងខ្លាំង ។ ព្រះពុទ្ធដិមាករដែលមាន រហូតដល់សព្វថ្ងៃនេះនៅវត្តអំពែរភ្នំគឺជាពុទ្ធដិមាករចាស់ៗ និងមានការកសាងថ្មីខ្លះៗ ។ ពុទ្ធដិមាករចាស់ៗទាំងនោះត្រូវបានប្រជាជននាំគ្នាដើររើសយកមកពីកន្លែងផ្សេងៗក្នុងបរិវេណវត្តមកដុះលាងហើយយកមកដាក់តំកល់នៅកន្លែងដើមវិញ បន្ទាប់ពីបានដុះលាងព្រះវិហារឲ្យអស់ឈាមរួចមក ។*

*ដើម្បីឲ្យដឹងច្បាស់ពីស្ថានភាពនៅវត្តអំពែរភ្នំកាលពីជំនាន់ខ្មែរក្រហមកាន់អំណាចថាមានរឿងរ៉ាវយ៉ាងណានោះ សូមអាននូវសម្ដីផ្ទាល់របស់អ្នកដឹងឮចំនួនបីរូបដូចខាងក្រោមៈ*

### ***ពុទ្ធដីការរបស់ព្រះសង្ឃព្រះនាមសុផល ហៅ ញ៉ែម ស៊ីន ព្រះជន្ម ៧១ វស្សា***

*សម័យសីហនុ និងសម័យលន់ ណុលមានស្រុកកំណើតនៅភូមិទួលទ្នង ឃុំវល្លិសរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។ ក្នុងរបបប៉ុលពតគឺវាបានបង្ហូរ(ជម្លៀស) ចេញទៅនៅស្រុកខវ៉ាល់ ។ក្រោយឆ្នាំ១៩៧៩ អាត្មាបានវិលមករស់នៅភូមិលាក់អន្ទូង ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។ អាត្មាបានបួសនៅវត្តអំពែភ្នំនេះតាំងពីឆ្នាំ១៩៨៨មករហូតសព្វថ្ងៃ ។ ក្រោយពីបានមករស់នៅក្នុងទីវត្តនេះ អាត្មាបានឃើញក្នុងទីអារាមវត្តមានឈាមបង្ហូរចេញពីព្រះវិហារទៅតាមជញ្ជាំងវិហារទៅក្រៅ ។ ក្រោយមកព្រះវិហារនេះក៏បានដុះលាងដោយបងប្អូនពុទ្ធបរិស័ទដែលធ្លាប់គោរពប្រណិបត្តិសាសនា ព្រមទាំងមានមន្ត្រីខ្លះជួយជួសជុលនូវពុទ្ធដិមាករដែលបាក់បែកនោះឡើងវិញ ។ នៅក្នុងទីវត្តអំពែរភ្នំទាំងមូលនៅប៉ែកខាងលិចមួយគីឡូម៉ែត្រខាងកើតវត្តដល់ភូមិ មួយគីឡូម៉ែត្រសុទ្ធតែជារណ្ដៅកប់ខ្មោចទាំងអស់ ព្រោះដឹងដោយសារកសិករដែលបានវិលត្រឡប់ពីកន្លែងនានាក្រោយពេលបែកមកជីកដី ដើម្បីបង្កបង្កើនផល ដាំដំណាំនៅទីនោះ ។ លុះដល់ពេលកាប់គាស់ទៅក៏ប្រទះឃើញមានឆ្អឹងខ្មោច ហើយបងប្អូនទាំងនោះក៏នាំគ្នាទៅប្ដឹងរដ្ឋអំណាច បន្ទាប់មកក៏មានការជីកគាស់មើលទៅក៏ប្រទះឃើញមានឆ្អឹងរយពាន់*

ពេញទីតាំងខាងលិចវត្តហ្នឹងតែម្តង ។ ការគាស់នៅតែបន្តរហូតដល់ជាងមួយឆ្នាំ ទើបខាងរដ្ឋអំណាចក៏បញ្ឈប់លែងឲ្យគាស់តទៅទៀត ព្រោះឆ្អឹងច្រើនពេកហើយគ្រប់កន្លែងទៀត ។ ហើយនៅពេលនោះរដ្ឋអំណាចបានចាប់ផ្តើមកសាងវត្តអារ៉ាមឡើងវិញ ហើយបានកសាងកន្លែងដាក់ឆ្អឹងទាំងនោះមួយផង ។

**សម្តីរបស់តា អ៊ុន ហាក់ អាយុ ៧២ ឆ្នាំ**

ខ្ញុំមានស្រុកកំណើតនៅភូមិអំពែរភ្នំ ឃុំរលាំងចក ស្រុកសំរោងទង ។ ក្រោយមករស់នៅឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ។ ជំនាន់ប៉ុលពត ក៏មិនបានទៅរស់នៅឯណាឆ្ងាយដែរ គឺទៅនៅក្បាលស្ពានឈ្មោះលួង (ច្បារមន) ។ បន្ទាប់មកគេ(ខ្មែរក្រហម) បានបញ្ជូនខ្ញុំឲ្យទៅនៅអង្គរបូរី (ស្រុកអង្គរបូរី ខេត្តតាកែវ) តំបន់៥៥ ។ នៅឆ្នាំ១៩៧៩ ខ្ញុំបានវិលត្រឡប់មកស្រុកកំណើតវិញ ។ ពេលមកដល់ខ្ញុំបានឡើងមកថ្វាយបង្គំព្រះនៅក្នុងវិហារ ប៉ុន្តែគ្មានព្រះសំរាប់ថ្វាយបង្គំទេ ។ នៅក្នុងព្រះវិហារនោះមានឃើញព្រះដីធំ (ព្រះអង្គធ្វើពីស៊ីម៉ង់ត៍ធំជាងគេ) ត្រូវពួកខ្មែរក្រហមបាញ់បាក់ក ហើយគ្រាប់កាំភ្លើងនោះបានហោះទៅត្រូវនឹងពិដានខាងលើរបើកមួយផ្ទាំងទៀត ។ ប្រជាជនដែលមកស្នាក់នៅហ្នឹង(ក្នុងព្រះវិហារ) បើតាមជំនឿព្រះពុទ្ធសាសនាគឺរត់ទៅឲ្យព្រះជួយ ហើយបន្ទាប់មកក៏ត្រូវពួកវា (ខ្មែរក្រហម) បាញ់សម្លាប់ទាំងអស់ទៀត ។ នៅលើបល្ល័ង្កព្រះធំនោះខ្ញុំឃើញមានសុទ្ធតែឈាមប្រឡាក់ពេញ ។ ក្រោយមកខ្ញុំបានបបួលគ្នាទៅរើសយកព្រះដែលកប់ក្នុងល្បាប់(ដីភក់ៗ) មកលាងទឹកដាក់លើបល្ល័ង្កវិញ ។ គំនូរជុំវិញជញ្ជាំងពួកវា(ខ្មែរក្រហម) លុបនឹងកំបោរសទាំងអស់ ។ ពេលនោះខ្ញុំបានភរ (កុហក) ប្រជាជនថា ពួកខ្មែរក្រហមបានយកស្ករមកដាក់លាក់នៅក្រោមបល្ល័ង្ក លុះក្រោយមកស្ករនោះបានកំពុបហើយហៀរពេញទីនោះ ហេតុដូច្នោះហើយទើបពួកយើងរាល់គ្នានាំគ្នារែកទឹកមកលាងចេញឲ្យស្អាត ។ ប៉ុន្តែតាមពិតជាឈាមទេ ។ ខ្ញុំធ្វើយ៉ាងនេះគឺកុំឲ្យគេខ្ពើបរអើម និងកុំឲ្យខ្លាច ។ បច្ចុប្បន្នគំនូរទាំងនោះស្អាតហាក់ដូចគំនូរដែលគ្មានប្រឡាក់ប្រឡូសអញ្ចឹង ដោយសារតែស្នាដៃប្រជាជនយើងនៅជុំវិញទីវត្ត ។ នៅថ្ងៃមួយនោះមានប្រជាជនមកជីកដីដើម្បីដាំដំណាំផ្សេងៗ ព្រោះពេលនោះ (១៩៧៩-៨០) ប្រជាជនយើងនៅមានភាពខ្វះខាត ។ ដល់ពេលភ្ជួរដីដាំដំណាំ ស្រាប់តែផ្លែរបស់នង្គ័លដែលភ្ជួរនោះអត់មុតសោះ ក៏មានការឆ្ងល់ក្នុងចិត្តក៏ក្រឡេកមើលទៅស្រាប់តែឃើញផ្លែនង្គ័លនោះទៅដោតជាប់ក្បាលខ្មោចមួយ ។ ពេលនោះមានមនុស្សម្នាក់និយាយថាដីត្រង់ណាដែលមានកប់ខ្មោចគឺប្រាកដជាមានវត្ថុដូចជាឆ្អឹង ។ មូលហេតុនេះហើយទើបជាមានសារៈមន្ទីរតំកល់អដ្ឋិធាតុនេះឡើង ព្រោះមានការគាស់ពីប្រជាជនធ្វើចំការ ។ ក្រោយមកទើបលោកចៅហ្វាយស្រុកឆាយ ខេង ទៅរៃអង្គៀសគ្រប់វត្តទាំងអស់ក្នុងខេត្ត ដោយក្នុងមួយវត្តៗជួយចេញចំនួន៣០០០រៀលយកមកសង់សារៈមន្ទីរនេះដើម្បីតំកល់អដ្ឋិធាតុដែលគាស់បាន ជៀសវាងកុំឲ្យមានភាពរប៉ាតរប៉ាយកណ្តាលវាល ។ ឆ្នាំដែលសង់

សារៈមន្ទីរនេះគឺនៅឆ្នាំ១៩៨៦ ។ ក្នុងចិត្តរបស់ខ្ញុំផ្ទាល់សន្និដ្ឋានថាទីតាំងព្រះវិហារនេះជាកន្លែងឃុំឃាំងអ្នកទោស ហើយក៏មានការសម្លាប់ខ្លះៗដែរនៅពេលដែលអ្នកទោសស្រែក ឬ ទ្រហោរយំដោយសារការធ្វើទណ្ឌកម្ម ។ ចំណែកកន្លែងក្រៅពីព្រះវិហារប៉ែកខាងលិច គឺខ្ញុំបានឃើញមានរណ្ដៅជាជួរៗហើយមានដំបងខ្នោះ ។ ដំបងនិងខ្នោះទាំងនេះមាននៅពាសពេញទីកន្លែងនៃកន្លែងសម្លាប់ ។ អដ្ឋិធាតុដែលបានគាស់ហើយ គឺមានចំនួនច្រើនជាងអដ្ឋិធាតុដែលមិនទាន់បានគាស់ ។ អដ្ឋិធាតុដែលបានប្រមូលមកដាក់នៅកន្លែងតំកល់អដ្ឋិធាតុនេះ មិនបានប្រមូលមកពីកន្លែងដទៃទេ ក្រៅពីកន្លែងនេះ«ប៉ែកខាងលិចព្រះវិហារ» ។ ប៉ុន្តែក៏មានឆ្អឹងភាគតិចដែរដែលយកមកពីបន្ទាយរោងគោ ព្រោះពេលនោះ«សម័យប៉ុលពត» ក៏មានកប់ ។ កាលនោះខ្ញុំបានដឹងថានៅភូមិមួយក្បែរបន្ទាយរោងគោមានផ្ទះមួយខ្នងតូចបានធ្វើបុណ្យសពកូនក្នុងឆ្នាំ១៩៧៩ ហើយពេលនោះម្ចាស់ផ្ទះក៏បានជីកដី ដើម្បីកប់ទឹកកកការពាររលាយព្រោះត្រូវត្រៀមដាក់ភេសជ្ជៈប្រគេនព្រះសង្ឃ ។ ពេលកំពុងជីកក៏ប្រទះឃើញឆ្អឹង ហើយក៏លែងជីកទៅ ។ ចាប់ពីធ្វើបុណ្យកូនរួច ម្ចាស់ផ្ទះក៏រើទៅនៅកន្លែងផ្សេងវិញ ។ ប្រជាជនដែលត្រូវបានអង្គការឲ្យមកកាន់វត្តអំពែរភ្នំ គឺមិនត្រូវបានរួចខ្លួនទេ ព្រោះមិនដែលបានប្រទះឃើញនរណាម្នាក់ដែលនៅរស់សោះ ។ កាលនោះខ្ញុំមានចិត្តស្ដាយព្រោះមិនបានមកវត្តអំពែរភ្នំជាមួយម្ដាយមីងដោយសារតែអង្គការមិនអនុញ្ញាតិ ។ ខ្ញុំសុំអង្គការមកនេះព្រោះយល់ថាមកកាន់វត្តអំពែរភ្នំគឺពិតជាបានរស់ស្រួល ស៊ីឆ្អាញ់មិនដឹងថាវា«ខ្មែរក្រហម» យកមកដាក់គុកយ៉ាងហ្នឹងសោះ ។ ប្រសិនជាអង្គការឲ្យខ្ញុំមកជាមួយម្ដាយមីងម្ល៉េះខ្ញុំបានដេកក្នុងផ្ទះក្បឿងមួយខ្នងនេះ(លោកអ៊ំបានចង្អុលទៅកន្លែងតំកល់អដ្ឋិធាតុដែលឈរជគ្រឹងនៅប្រមាណជា៨ម៉ែត្រពីកន្លែងឈរសម្ភាសន៍) បាត់ទៅហើយ (នេះជាសម្ដីនិយាយលេងរបស់អ៊ំប្រុស) ។ ពេលខ្ញុំរត់មកដល់ទីវត្តនេះខ្ញុំបានឃើញនៅក្នុងបរិវេណវត្តមានខ្ទះសម្ល្របព្រលិតនៅពេញទាំងខ្ទះ មានបាយមានប្រហុក ព្រោះពួកវា«ខ្មែរក្រហម»ទើបតែរត់ថ្មីនេះ ។ ចំពោះអ្នកស្លាប់នៅទីនេះ តាមខ្ញុំដឹងគឺមានក្បួនតម្រា(បញ្ជី) គេកត់ត្រឹមត្រូវ ប៉ុន្តែមិនដឹងជាលោក(ព្រះសង្ឃ)ទុកនៅហ្នឹង ឬភាគច្រើនៗតែចៅហ្វាយស្រុកយកទៅសម្រាប់ធ្វើសម្ភាសន៍ផ្សេងៗ ។ ខ្ញុំអាចប៉ាន់ស្មានថា ចំនួនអ្នកស្លាប់មិនក្រោមពី៧០០០០នាក់ទេ ។

## សម្ដីរបស់អាចារ្យវត្តអំពែរភ្នំឈ្មោះ ឆាយ ចេង អាយុ៧០ឆ្នាំ

នៅសម័យខ្មែរក្រហមខ្ញុំរស់នៅរលាំងក្រើល ។ ដំបូងបំផុតខ្ញុំរស់នៅត្រពាំងថ្ម ស្រង់[៥] ។ ១៩៧៥ ខ្ញុំចុះពីស្រង់មកនៅរលាំងក្រើល ។ ១៩៧៩ ខ្ញុំមកនៅជ្រុកឈើទាលខាងជើងស៊ីង ។

---

[៥] ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

១៩៨០ ខ្ញុំមកនៅភូមិត្រពាំងថ្កូវ ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។ ខ្ញុំមកកាន់កិច្ចការវត្តនេះតាំងពី១៩៧៩ ។ ពេលនោះខ្ញុំបានឃើញនៅមានកុដិ និង សាលា(សាលាឆាន់) ប៉ុន្តែមានតែដំបូលទេ ជញ្ជាំងអស់ហើយ រនាបក៏អស់ដែរ ។ ពួកខ្មែរក្រហមមានទីតាំងនៅសាលាបាលីហើយមានដាក់ថ្នាំពេទ្យ“ថ្នាំអាចម៍ទន្សាយ” នៅទីនោះដែរ ។ មានមន្ទីរសេដ្ឋកិច្ចនៅក្បែរនោះដែរ ។ ពួកខ្មែរក្រហមដែលនៅគ្រប់គ្រងវត្ត(វត្តអំពែរភ្នំ) នេះសុទ្ធតែជាជនពិការ ។ ហើយពួកនេះក៏ជាអ្នកផលិតថ្នាំនិងធ្វើទារុណកម្មទៅលើហ្វូងអ្នកទោស ។ ខ្ញុំសន្និដ្ឋានថាកន្លែងសួរចម្លើយគឺស្ថិតនៅលើព្រះវិហារព្រោះឃើញមានស្នាមឈាម ។ ចំណែកកន្លែងសម្លាប់គឺស្ថិតនៅត្រង់ណោះ(ជើងភ្នំខាងលិចព្រះវិហារ) មួយដែលមានបណ្តោយ៣ម៉ែត្រ២ម៉ែត្រទទឹងជំរៅ១ម៉ែត្រ ។ បើតាមការនិយាយតគ្នាមកថា នៅនឹងគល់ដើម..........ដែលនៅក្នុងបរិវេណវត្តអំពែរភ្នំ គឺពួកខ្មែរក្រហមបានយកមនុស្សមកដាក់ឆ្កាងជាប់នឹងគល់នៃដើមឈើនោះ រួចវះពោះយកថ្លើមនឹងប្រម៉ាត់ ។ អ្នកទោសដែលពួកខ្មែរក្រហមចាប់មកដាក់ឆ្កាងមានម្នាក់(មិនស្គាល់ឈ្មោះ មិនដឹងអាស័យដ្ឋាន) បានរួចខ្លួនពីសេចក្តីស្លាប់ ដោយសារតែពួកវាសម្លាប់មិនទាន់ ។ មានការសម្លាប់ច្រើនបំផុតនៅចុងឆ្នាំ១៩៧៨ ។ ខ្ញុំបានឃើញឡានចំនួនប្រហែលជាង៣០ឡានដាក់ពេញៗ ។ ពេលខ្ញុំសួរអ្នកដែលជិះលើឡាននោះ គេនិយាយថាដឹកយកទៅស្រុក មិនមែនយកទៅសម្លាប់ទេ ។ អ្នកទាំងនោះគឺសុទ្ធតែមានការស្ម័គ្រចិត្តមកតាមពាក្យសម្តីរបស់ពួកខ្មែរក្រហមនិយាយថា «បើនរណាចង់ទៅស្រុក មកឡើងឡាន» ។ កន្លែងសម្លាប់គឺមានតែនៅក្នុងបរិវេណវត្ត និងខាងលិចវត្ត ប៉ុណ្ណោះ ។

---